# សេចក្តីណែនាំចាប់ផ្តើមរហ័ស ដើម្បីអនុញ្ញាត វេន ក្នុងផតថល **evvie** បានធ្វើបច្ចុប្បន្នភាពនៅខែមេសាឆ្នាំ 2022

វាងាយស្រួលក្នុងការអនុញ្ញាតវេននៅក្នុងកម្មវិធីវិបផតថល **evvie** ។ FMS Provider គួរតែបានផ្ញើអ៊ីមែលអំពីសេចក្តីណែនាំទៅកាន់អ្នករួចហើយសម្រាប់ការដំឡើងគណនី **FMSOne** របស់អ្នក។ អ្នកត្រូវតែមានឈ្មោះអ្នកប្រើ **FMSOne** និងពាក្យសម្ងាត់ ដើម្បីប្រើប្រាស់កម្មវិធីវិបផតថល **evvie** ។ ប្រសិនបើអ្នកមិនទាន់បានដំឡើងការឡុកចូលរបស់ **FMSOne** នៅឡើយ សូមពិនិត្យមើលតារាងណែនាំសម្រាប់ការដំឡើងវា មុនពេលអ្នកព្យាយាមចុះឈ្មោះចូលកម្មវិធីវិបផតថល **evvie** ។

ចូរពិនិត្យមើលជំហានមួយចំនួនសម្រាប់ការអនុញ្ញាតលើវេនរបស់អ្នក។

| | **ជំហានដែលត្រូវបំពេញ** | **រូបរាងដែលវាបង្ហាញនៅលើអេក្រង់** |
|---|---|---|
| 1 | បើកកម្មវិធីមើលវិបរបស់អ្នក ហើយចូលតាមតំណទៅកាន់កម្មវិធីវិបផតថល **evvie** របស់អ្នក។ យើងបានផ្ញើតំណទៅអ្នកនៅក្នុងអ៊ីមែលអញ្ជើញ និងអ៊ីមែលស្វាគមន៍ដែលអ្នកបានទទួលនៅពេលចុះឈ្មោះ។ ចុះឈ្មោះចូលដោយប្រើ **FMSOne** ។ |   *1 - អេក្រង់ឡុកចូល* |
| 2 | ចុចប៊ូតុង **"View all Shift" (មើលវេនទាំងអស់)** ដែលមានពណ៌ខៀវ។ |   *2- ប៊ូតុង View All Shifts (មើលវេនទាំងអស់)* |
| 3 | ស្វែងរក ឬរកមើលលិបិក្រមសម្រាប់វេននៅក្នុងស្ថានភាព បានដាក់បញ្ជូន ឬបានអនុញ្ញាត។ ចុចលើប៊ូតុង **View Shift (មើលវេន)** នៅក្នុងបញ្ជី នៅជាប់នឹងវេនដែលអ្នកចង់អនុញ្ញាត។ អ្នកទីមួយដែលត្រូវអនុញ្ញាត នឹងរកមើលវេន ដែលបានដាក់បញ្ជូន ដើម្បីអនុញ្ញាត អ្នកទីពីរនឹងរកមើលវេន ដែលបានអនុញ្ញាតិ ដើម្បីដាក់នៅក្នុងស្ថានភាព បានចាក់សោការអនុញ្ញាត។ |   *3- ប៊ូតុង View Shift (មើលវេន)* |
| 4 | បន្ទាប់ពីមើលវេនរួច ចូររំកិលទៅផ្នែកខាងក្រោមនៃអេក្រង់ ហើយចុចលើប៊ូតុង **Approve Shift (អនុញ្ញាតវេន)** ឬ **Lock as Approved (ចាក់សោជា បានអនុញ្ញាត)** ដែលមានពណ៌បៃតង។ |     ប៊ូតុង Approve Shift (អនុញ្ញាតវេន) *ប៊ូតុង Lock as Approved (ចាក់សោជា បានអនុញ្ញាត* |
| 5 | បញ្ចូលមតិយោបល់ណាមួយ បន្ទាប់មកគូសប្រអប់ធីក ដើម្បីបញ្ជាក់វេន។ ជំហានចុងក្រោយគឺ ចុចលើប៊ូតុង **Submit Approval (ដាក់បញ្ជូនការអនុញ្ញាត)** ឬ **Lock as Approved (ចាក់សោជា បានអនុញ្ញាត)** ដែលមានពណ៌បៃតង។ ឥឡូវនេះ វេនត្រូវបានអនុញ្ញាតហើយ ឬការអនុញ្ញាតត្រូវបានចាក់សោ។ ប្រសិនបើអនុញ្ញាត អ្នកទីពីរនឹងត្រូវបំពេញដំណើរការចាក់សោការអនុញ្ញាតមុនពេលបញ្ជូនវេនទៅកាន់បញ្ជីប្រាក់ខែសម្រាប់ដំណើរការ។ |     *4- ប្រអប់មតិយោបល់ និងប៊ូតុង Approve (អនុញ្ញាត)* |

ប្រសិនបើអ្នកមានសំណួរបន្ថែម សូមអានសៀវភៅណែនាំអ្នកប្រើប្រាស់របស់ **evvie** ឬទាក់ទង FMS Provider របស់អ្នកសម្រាប់ជំនួយ។

ANNKISSAM An HHAeXchange Company

©Annkissam ឆ្នាំ 2022